*សេចក្តីថ្លែងការណ៍ក្រុងហូជីមិញ*

# ទឹក ថាមពល និងសន្តិសុខស្បៀង នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ សម្រាប់អាងទន្លេមេគង្គ

ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៤

## បុព្វកថា

យើង ប្រមុខរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជួបប្រជុំនៅក្រុងហូជីមិញ នៃប្រទេសវៀតណាម ក្នុងកិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ។

យើងអះអាងឡើងវិញអំពីសារៈសំខាន់ជាអាយុជីវិតនៃការប្រើប្រាស់ និងគ្រប់គ្រងទឹក និងធនធានដែលពាក់ព័ន្ធនៃអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព និងការប្តេជ្ញានយោបាយដើម្បីបន្តការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និងពង្រឹងស្មារតីនៃកិច្ចសហប្រតិបត្តិការទន្លេមេគង្គ។

យើងកត់សំគាល់ថា ការអភិវឌ្ឍធនធានទឹកនៃអាងទន្លេមេគង្គ បានរួមចំណែកយ៉ាងច្រើនចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងតំបន់នេះ ដូចជា សម្រាប់នាវាចរ ការផលិតថាមពល និងស្បៀង ប៉ុន្តែក៏មានផលប៉ះពាល់អវិជ្ជមានខាងបរិស្ថាន និងសង្គម នៅក្នុងអាងទន្លេនេះផងដែរ ដែលចាំបាច់ត្រូវដោះស្រាយឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។

យើងទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាសកល ដែលបង្កការប៉ះពាល់មកលើបរចិញ្ចឹមជីវិត និងសេដ្ឋកិច្ច នៅគ្រប់កន្លែងទាំងអស់នៃអាងទន្លេមេគង្គ។ ការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ មានសារៈសំខាន់ខ្លាំងណាស់ និងចាំបាច់ត្រូវដោះស្រាយជាបន្ទាន់។

យើងរម្លឹកឡើងវិញនូវសកម្មភាពអាទិភាព និងការប្តេជ្ញានៅក្នុងកិច្ចប្រជុំកំពូលលើកទីមួយនៃគណៈកម្មការទន្លេមេគង្គ ដែលរួមទាំង ការអនុម័ត និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដែលផ្អែកលើគោលការណ៍គ្រប់គ្រងទឹកចម្រុះនៃគណៈកម្មការទន្លេមេគង្គ ផែនការយុទ្ធសាស្ត្រឆ្នាំ ២០១១-២០១៥ របស់គណៈកម្មការទន្លេមេគង្គ និងការកំណត់អត្តសញ្ញាណឱកាស និងហានិភ័យនៃថាមពលវារីអគ្គិសនី ការស្រោចស្រពការនេសាទ នាវាចរ ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ការគ្រប់គ្រងទីជម្រាល ទេសចរណ៍ និងបរិស្ថានដែលរួមទាំង ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី នៅក្នុងអាងទន្លេនេះ ដើម្បីសន្តិសុខស្បៀង និងរបរចិញ្ចឹមជីវិត។

យើងអះអាងឡើងវិញអំពីការប្តេជ្ញាមោះមុត និងជាបន្តរបស់យើងនៅក្នុងកិច្ចសហប្រតិបត្តិការ និងការលើកកំពស់ការអភិវឌ្ឍអាងទន្លេមេគង្គដោយចីរភាព និងក្នុងការប្រើប្រាស់ ការអភិរក្ស និងការគ្រប់គ្រងទឹក និងធនធានដទៃទៀតនៃទន្លេនេះ និងឯកភាពចំពោះសេចក្តីថ្លែងការណ៍ដូចតទៅ៖

## សមិទ្ធផលគិតចាប់ពីកិច្ចប្រជុំកំពូលលើកទីមួយនៃគណៈកម្មការទន្លេមេគង្គ

យើង ប្រមុខរដ្ឋាភិបាល ទទួលស្គាល់វឌ្ឍនភាព និងសមិទ្ធផលរយៈពេលបួនឆ្នាំកន្លងមក គិតចាប់ពីកិច្ចប្រជុំកំពូលលើកទីមួយនៃគណៈកម្មការទន្លេមេគង្គ។

ចាប់តាំងពីការអនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដោយផ្អែកលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះនៃគណៈកម្មការទន្លេមេគង្គនៅឆ្នាំ ២០១១ យើងកត់សំគាល់ជាមួយការកោតសរសើរថា ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការនេះ បានធ្វើការប្រឹងប្រែងជាច្រើន ដើម្បី

កសាងផែនការសកម្មភាពថ្នាក់តំបន់ និងថ្នាក់ជាតិ សម្រាប់អនុវត្តយុទ្ធសាស្ត្រ ដែលជាការបំពេញបន្ថែមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមនៃប្រទេសជាសមាជិក។

យើងទទួលស្គាល់ការអនុវត្តបានទូលាយជាងមុននៃនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចគ្រប់ជ្រុងជ្រោយអំពីគម្រោងសំណើគម្រោងអភិវឌ្ឍន៍ធនធានទឹកក្នុងអាងទន្លេមេគង្គ។

យើងរីករាយក្នុងការកត់សំគាល់ថា ការអនុម័តឯកភាពលើនីតិវិធីគុណភាពទឹកនៅដើមឆ្នាំ ២០១១ ជាការបំពេញទាំងស្រុងលើនីតិវិធីប្រើប្រាស់ទឹកនៃគណៈកម្មការទន្លេមេគង្គ ដែលផ្តល់ជាក្របខណ្ឌនីតិវិធី និងបច្ចេកទេស ដើម្បីជួយប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គក្នុងការប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព។

យើងកត់សំគាល់អំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការបន្តផ្តោះប្តូរទិន្នន័យនិងព័ត៌មានក្នុងចំណោមប្រទេសជាសមាជិក នៅក្រោមនីតិវិធីផ្តោះប្តូរ និងចែករម្លែកទិន្នន័យ និងព័ត៌មាន (PDIES) ហើយយើង វាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំជាមួយដៃគូសន្ទនារបស់គណៈកម្មការទន្លេមេគង្គ ពោលគឺសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

យើងទទួលស្គាល់វឌ្ឍនភាពដែលសម្រេចបាននៅក្នុងការដាក់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គឲ្យស្ថិតក្រោមប្រតិបត្តិការនៃអ្នកជំនាញការពីប្រទេសតាមដងទន្លេនេះ ទន្ទឹមនឹងការប្រកាសចាប់ផ្តើមដោយជោគជ័យនូវកម្មវិធីអ្នកជំនាញវ័យក្មេងនៃគណៈកម្មការទន្លេមេគង្គ និងការកើនឡើងនៃចំនួនបុគ្គលិកពីប្រទេសតាមដងទន្លេនេះ និងជំនាញការជាតិដែលធ្វើការនៅក្នុងលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

ជាមួយចក្ខុវិស័យដើម្បីឲ្យគណៈកម្មការទន្លេមេគង្គមាននិរន្តរភាពហិរញ្ញវត្ថុឧបត្ថម្ភដោយប្រទេសជាសមាជិកចាប់ពីឆ្នាំ២០៣០ យើងទទួលស្គាល់ជាមួយការកោតសរសើរចំពោះការត្រៀមរៀបចំដែលបានធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ សម្រាប់វិមជ្ឈការនៃការអនុវត្តមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេ ដូចមានចែងនៅក្នុងផែនទីបង្ហាញផ្លូវថ្នាក់តំបន់មួយ និងផែនទីបង្ហាញផ្លូវថ្នាក់ជាតិចំនួនបួន ដែលរួមមានទាំងអាទិភាព និងចំណុចគោលនានាផងដែរ។

យើងរីករាយដោយឃើញកំណើនការគាំទ្រខាងហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដែលនឹងទ្រទ្រង់កម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គបន្តពីឆ្នាំ ២០១៥ទៅទៀត និងការត្រៀមរៀបចំសម្រាប់ស្វ័យភាពខាងហិរញ្ញប្បទានចាប់ពីឆ្នាំ ២០៣០ទៅ។

យើងកត់សំគាល់ផងដែរថា គណៈកម្មការទន្លេមេគង្គបានបង្កើតទំនាក់ទំនងដែលដំណើរបានល្អជាមួយអាស៊ាន និងគណៈកម្មការទន្លេមីស៊ីស៊ីពី និងបានស្វែងយល់ពីភាពបំពេញគ្នាជាមួយកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីជម្រុញបន្ថែមទៀតនូវការអភិវឌ្ឍដោយចីរភាព និងការគ្រប់គ្រងធនធានទឹកក្នុងអាងទន្លេមេគង្គ។

យើងទទួលស្គាល់ជាមួយការកោតសរសើរចំពោះសមិទ្ធផលរបស់ *Mekong$_2$Rio: សន្និសីទអន្តរជាតិស្តីពីការគ្រប់គ្រងអាងទន្លេឆ្លងដែន* ដែលបានធ្វើឡើងកាលពីថ្ងៃ ១-៣ ខែ ឧសភា ឆ្នាំ ២០១២ នៅភូកេត ប្រទេសថៃ និង*សន្និសីទអន្តរជាតិស្តីពីកិច្ចសហប្រតិបត្តិការដើម្បីទឹក ថាមពល និងសន្តិសុខស្បៀងក្នុងអាងទន្លេឆ្លងដែននៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ* ដែលបានធ្វើឡើងនៅថ្ងៃទី ២-៣ ខែ មេសា ឆ្នាំ២០១៤ នៅ

ទីក្រុងហូជីមិញ ប្រទេសវៀតណាម ដែលបានផ្តល់ឱកាសដ៏ប្រសើរដើម្បីចែករំលែក និងរៀនសូត្រពីបទពិសោធន៍កម្រិតពិភពលោកអំពីការអភិវឌ្ឍ និងការគ្រប់គ្រងទឹកឆ្លងដែន។

## ឱកាស និងការប្រឈមនៅកម្រិតតំបន់

យើង ប្រមុខរដ្ឋាភិបាល ទទួលស្គាល់ថា គណៈកម្មការទន្លេមេគង្គប្រឈមជាមួយទាំងឱកាស និងការលំបាកនានានៅក្នុងទសវត្សរ៍ខាងមុខនេះ។

កំណើនសម្ពាធនៃការអភិវឌ្ឍ ដូចជា កំណើនចំនួនប្រជាជន និងការពង្រីកសេដ្ឋកិច្ច បង្កើតឲ្យមានតម្រូវការទឹក ស្បៀងអាហារ និងថាមពលយ៉ាងច្រើន ដែលបង្កជាបន្ទុកធ្ងន់ធ្ងរ មកលើធនធានទន្លេមេគង្គ។ ទន្ទឹមនឹងនេះ វិបត្តិសេដ្ឋកិច្ចពិភពលោក បានកាត់បន្ថយការវិនិយោគ និងមូលនិធិដែលមានសម្រាប់កម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គ។ ការជានាសន្តិសុខទឹក និងលុបបំបាត់ហានិភ័យកាន់តែច្រើនជាងមុននៅចំពោះមុខ សម្រាប់ស្បៀងអាហារ និងសន្តិសុខថាមពល កំណើនសេដ្ឋកិច្ច និងស្ថិរភាព គឺជាការប្រឈមដ៏លំបាកមួយសម្រាប់តំបន់នេះក្នុងពេលសព្វថ្ងៃ។

នៅក្នុងការបន្តកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយគ្រោះមហន្តរាយធម្មជាតិ យើងទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុនឹងបន្តធ្វើឲ្យប្រែប្រួលរបបជលសាស្ត្រនៃអាងទន្លេនេះ ដែលបង្កការប៉ះពាល់ចំពោះរបរចិញ្ចឹមជីវិត និងសេដ្ឋកិច្ចនៅក្នុងកន្លែងទាំងអស់នៃអាងទន្លេនេះ។

យើងទទួលស្គាល់ពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍអាងទន្លេមេគង្គដោយចីរភាព។ យើងត្រូវស្វែងយល់ពីឱកាសសម្រាប់កិច្ចសហប្រតិបត្តិការថ្មីៗជាមួយកិច្ចផ្តួចផ្តើមដទៃទៀតនៅថ្នាក់តំបន់ និងអន្តរជាតិ ត្រូវស្វែងរកការគាំទ្រមូលនិធិ និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ថ្មីៗ ដើម្បីជួយទ្រទ្រង់ និងធានាថា គណៈកម្មការទន្លេមេគង្គអាចបន្តការងារដ៏សំខាន់របស់ខ្លួន។

## វិស័យនៃសកម្មភាពជាអាទិភាព

យើង ប្រមុខរដ្ឋាភិបាល រំពឹងថាគណៈកម្មការទន្លេមេគង្គនឹងផ្តោតលើ និងចាត់ជាអាទិភាពនូវះ

i. ការបង្កើនល្បឿនការអនុវត្តការសិក្សារបស់ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គដោយនិរន្តរភាព ដែលរួមទាំងផលប៉ះពាល់នៃគម្រោងថាមពលវារីអគ្គិសនីលើដងទន្លេមេ ក្នុងការសម្របសម្រួលជាមួយការសិក្សាអំពីដែនដីសណ្តទន្លេមេគង្គ ដែលផ្តួចផ្តើមដោយប្រទេសវៀតណាម ដើម្បីផ្តល់យោបល់ និងអនុសាសន៍គ្រប់ជ្រុងជ្រោយអំពីការអភិវឌ្ឍអាងទន្លេនេះដោយនិរន្តរភាព។

ii. ការពិនិត្យ ធ្វើបច្ចុប្បន្នភាព និងការអនុវត្តយុទ្ធសាស្ត្រអាងទន្លេដោយផ្អែកលើគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ និងការអនុវត្តយុទ្ធសាស្ត្រឆ្នាំ ២០១១-២០១៥ របស់គណៈកម្មការទន្លេមេគង្គ, ការរៀបចំ និងការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ ដើម្បីជួយកែលម្អការអភិវឌ្ឍនៅក្នុងអាងទន្លេមេគង្គនាពេលបច្ចុប្បន្ន និងទៅអនាគត។

iii. បញ្ចៀស កាត់បន្ថយ និងបន្ធូរបន្ថយហានិភ័យចំពោះអេកូឡូស៊ីទន្លេ សន្តិសុខស្បៀង របរចិញ្ចឹមជីវិត និងគុណភាពទឹក ដែលបង្កដោយប្រពលវប្បកម្មកសិកម្ម វារីវប្បកម្ម និងការស្រោចស្រព ក៏ដូចជា ថាមពលវារីអគ្គិសនី នាវាចរ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងទៀតនៅក្នុងអាងទន្លេនេះ, ការទទួលស្គាល់ថា ផលប៉ះពាល់នានានៃការប្រែប្រួលអាកាសធាតុអាចធ្វើឲ្យហានិភ័យទាំងនេះ

កាន់តែធ្ងន់ធ្ងរ។

iv. ការបន្តកែលម្អការអនុវត្តនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គដើម្បីគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥, ការប្តេជ្ញាក្នុងការអនុវត្តនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចគោលដៅនានារបស់ខ្លួន។

v. ស្វែងយល់ និងកំណត់អត្តសញ្ញាណឱកាសដើម្បីពង្រីកកិច្ចសហប្រតិបត្តិការរវាងដៃគូសន្ទនារបស់គណៈកម្មការទន្លេមេគង្គ ដៃគូអភិវឌ្ឍន៍បច្ចុប្បន្ន និងថ្មីៗ និងកិច្ចផ្តួចផ្តើមដទៃទៀតនៅថ្នាក់តំបន់ និងអន្តរជាតិ។

vi. បង្កើនកិច្ចប្រឹងប្រែងក្នុងការកាត់បន្ថយហានិភ័យនៃទឹកជំនន់ គ្រោះរាំងស្ងួតនៅទូទាំងអាងទន្លេ និងផលប៉ះពាល់នៃកំនើននីវ៉ូទឹកសមុទ្រ, ការពិនិត្យតាមដាន និងចាត់វិធានការដើម្បីរក្សាគុណភាពទឹកនៅក្នុងអាងទន្លេមេគង្គឲ្យបានល្អ។

**ជំហានទៅមុខ**

យើង ប្រមុខរដ្ឋាភិបាល អះអាងឡើងវិញនូវសាមគ្គីភាពរបស់យើង និងកម្រិតខ្ពស់បំផុតនៃការប្តេជ្ញាខាងនយោបាយ ក្នុងការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥។

យើងប្តេជ្ញាធ្វើការជាមួយគ្នា ដើម្បីពង្រឹងតួនាទីរបស់គណៈកម្មការទន្លេមេគង្គ ក្នុងការធានាការអនុវត្តគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ដើម្បីធានាការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សទឹក ស្បៀងអាហារ និងធនធានថាមពលនៅក្នុងតំបន់នេះ។

យើងអះអាងឡើងវិញនូវការគាំទ្ររបស់យើងក្នុងការបង្កើន និងពង្រឹងទំនាក់ទំនងការងារ និងកិច្ចសហប្រតិបត្តិការរបស់គណៈកម្មការទន្លេមេគង្គជាមួយដៃគូសន្ទនា ដៃគូអភិវឌ្ឍន៍ កិច្ចផ្តួចផ្តើមអន្តរជាតិ និងតំបន់ សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នដទៃទៀត, និងអំពាវនាវសុំការគាំទ្រ និងជំនួយពីស្ថាប័នទាំងនោះដល់គណៈកម្មការទន្លេមេគង្គ និងប្រទេសនីមួយៗជាសមាជិករបស់គណៈកម្មការទន្លេមេគង្គ នៅក្នុងការអនុវត្តគម្រោង និងការសិក្សានានាអំពីការអភិវឌ្ឍអាងទន្លេមេគង្គឲ្យមាននិរន្តរភាព។

យើងសំដែងការគាំទ្ររបស់យើងដល់គណៈកម្មការទន្លេមេគង្គ ដើម្បីបន្តការត្រៀមរៀបចំធ្វើសមាហរណកម្មមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ ដែលផ្តល់ជាមាគ៌ាដើម្បីឲ្យអង្គការនេះមានស្វ័យភាពខាងហិរញ្ញប្បទានចាប់ពីឆ្នាំ ២០៣០។

យើងសង្កត់ធ្ងន់លើតម្រូវការដើម្បីចាត់ទុកការកសាងសមត្ថភាពសម្រាប់ប្រទេសជាសមាជិកថាជាអាទិភាព។

យើងឯកភាពចំពោះតួនាទីរបស់ក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គក្នុងការធានាការអនុវត្តសេចក្តីថ្លែងការណ៍នេះឲ្យមានប្រសិទ្ធភាព តាមរយៈកម្មវិធី និងគម្រោងជាក់ស្តែង។

យើងសំដែងការកោតសរសើរដោយស្មោះស្ម័គ្រចំពោះប្រទេសវៀតណាមដែលបានធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ ហើយយើងរំពឹងថានឹងមានកិច្ចប្រជុំកំពូលលើកទីបីនៃគណៈកម្មការទន្លេមេគង្គ ដែលនឹងធ្វើឡើងនៅខែមេសា ឆ្នាំ ២០១៨ នៅកម្ពុជា។

*បានអនុម័តលើសំណៅជាភាសាអង់គ្លេសនៅទីក្រុងហូជីមិញ ប្រទេសវៀតណាម នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៤ ។*